# ព្រះគ្រូចៅអធិការវត្តសាមគ្គីធម្មិការាម ព្រះភិក្ខុ សំវរសីលោ ឡុង មាន បានបូជាព្រះភ្លើងតាមទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនាខ្មែរហើយ

ព្រះភិក្ខុ សំវរសីលោ ឡុង មាន បានទទួលអនិច្ចធម្មនៅថ្ងៃសៅរ៍ ១១ កើត ខែបុស្ស ឆ្នាំខាល ទោស័ក ព.ស.២៥៥៤ ត្រូវនឹងថ្ងៃទី ១៥ ខែមករា គ.ស.២០១១ វេលាម៉ោង ៤:៣០នាទីទៀបភ្លឺ ក្នុងព្រះជន្មាយុប្រមាណ ៩២វស្សា ដោយរោគាពាធ នៅបូរីនូយ៉ក រដ្ឋនូយ៉ក សហរដ្ឋអាមេរិក ។

ព្រះអង្គប្រសូតនៅថ្ងៃទី ១៩ ខែឧសភា គ.ស.១៩១៩ នៅក្នុងភូមិក្លឿងរាយ ឃុំក្លឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ព្រះរាជាណាចក្រកម្ពុជា សម័យអាណានិគមបារាំងត្រួតត្រាកម្ពុជា ជាបុត្រទីពីររបស់ឧបាសក ឡុង មាស ។

ព្រះតេជព្រះគុណមានបងប្អូនបង្កើតរួមឧទ្ទរ ៤នាក់ បងប្រុសឈ្មោះ ឡុង ឆាំ ទីពីរគឺព្រះសព សំវរសីលោ ឡុង មាន ទីបីឈ្មោះ ឡុង បាន និងទីបួនឈ្មោះ ឡុង មឿន ។ បងប្អូនទាំងបីនាក់នេះបានធ្វើកាលកិរិយាលាចាកលោកនេះជាយូរយារណាស់ទៅហើយ ។

មុនពេលចូលសាងផ្នួស ព្រះភិក្ខុ សំវរសីលោ បានរៀបអាពាហ៍ពិពាហ៍ជាមួយឧបាសិកា ម៉ី ស៊ីថូ នាគ.ស.១៩៤២ ។ លោកយាយ ម៉ី ស៊ីថូ បានទទួលមរណភាពប្រាំបីឆ្នាំមុនព្រះអង្គនៅគ.ស.២០០២ ។ បុត្រ ៨នាក់របស់ព្រះសព និងលោកយាយ ម៉ី ស៊ីថូ មានប្រុស ២នាក់ និងស្រី ៦នាក់ គឺលោក ឡុង សុវណ្ណ ហៅនាង លោក មាស សំអុល ហៅទូច អ្នកស្រី មាស សុផន អ្នកស្រី មាស សុផល អ្នកស្រី មាស សុផាត អ្នកស្រី មាស សំណាង អ្នកស្រី មាស ស្រីពៅ និងអ្នកស្រី មាស សុភាព ។

នៅគ.ស.១៩៨០ ដោយពុំអាចទ្រាំរស់នៅក្រោមនឹមត្រួតត្រារបស់ពួកបនយួនឈ្លានពានវាតទីទឹកដីកម្ពុជាបាន ព្រះតេជព្រះគុណ សំវរសីលោ បានសម្រេចព្រះទ័យចាកចេញចោលមាតុភូមិជាទីស្រឡាញ់ ដឹកកូនជញ្ជូនចៅ ភៀសខ្លួនទៅសុំសិទ្ធិជ្រកកោន នៅជំរំជនភៀសខ្លួន ខៅអ៊ីដាង និងឈុនបូរី នៅតាមដងព្រំប្រទល់ដែនខ្មែរ-សៀម អតីតទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ព្រះអង្គបានចូលសាងផ្នួសតាំងពីគ.ស.១៩៨៧ ហើយបានគង់នៅជួយវត្តសាមគ្គីធម្មិការាមតាំងពីពេលនោះរហូតមកដល់បច្ចុប្បន្នកាលនេះ (គ.ស.២០១១) មានថេរៈវេលាប្រមាណ ២៤ឆ្នាំ ។

ព្រះអង្គបួសជាសាណេរនៅវត្តសាមគ្គីធម្មិការាម ប្រ៊ុកលីន ជាមួយព្រះឧបជ្ឈាយ៍ សុវណ្ណជោតោ អ៊ុក ច័ន្ទហន បច្ចុ-ប្បន្នជាព្រះគ្រូចៅអធិការវត្តពុទ្ធិការាម រដ្ឋធានី Washington, D.C. ។ រីឯព្រះឧបសម្បទាចាររបស់ព្រះអង្គក្នុងពេលបំពេញឧបសម្បទាជាភិក្ខុភេទវិញមិនមានប្រភពព័ត៌មានច្បាស់លាស់នៅឡើយ នៅពេលផ្សាយនេះ ។

នៅគ.ស.២០០៤ រហូតមកដល់បច្ចុប្បន្នកាលនេះ ព្រះអង្គមានអាពាធយ៉ាងធ្ងន់ ជាជម្ងឺមហារីកតម្រងនោម។ លោកវេជ្ជបណ្ឌិតធ្លាប់បានទូលប្រគេនព្រះអង្គថា ព្រះអង្គអាចនឹងគង់មានព្រះជន្មបានតិចជាងមួយឆ្នាំ ទោះជាវះកាត់ ឬមិនវះកាត់ក្តី ក៏ប៉ុន្តែជាក់ស្តែង ព្រះអង្គអាចនៅគង់មានព្រះជន្មបានរហូតដល់ជាងប្រាំមួយឆ្នាំ។

នេះក៏ដោយសារតែកុសលផលានិសង្ស ដែលកើតឡើងអំពីព្រះទ័យប្រកបដោយព្រហ្មវិហារធម៌ និងការលះបង់ដ៏ធំធេងរបស់ព្រះសពចំពោះមនុស្សសត្វទូទៅ។ តែទោះជាយ៉ាងណាក៏ដោយ រោគាប្រចាំកាយព្រះអង្គចេះតែមានសភាពធ្ងន់ធ្ងរទៅៗជាលំដាប់ ពិសេសនៅក្នុងកំឡុងពេលពីរសប្តាហ៍ចុងក្រោយនេះ។ ព្រះតេជព្រះគុណ សំវរសីលោ បានបាត់បង់ស្មារតី ភ្លឹកជាញឹកញាប់ ដោយគុណបុណ្យបារមីនៃព្រះធម៌ ព្រះបរិត្ត ដែលព្រះភិក្ខុ កល្យាណធរោ ធម៌ ប៊ុនធឿន បានស្វាធ្យាយជាប្រចាំក្នុងមួយថ្ងៃពីរ ឬបីដង ដើម្បីបង្កើនកម្លាំងកាយដាស់សតិស្មារតី។ មានពេលខ្លះ ព្រះអង្គក៏បានភ្ញាក់ស្មារតីឡើងវិញ បើកព្រះកាណ៌ ព្រះនេត្រ ព្រះឱស អាចស្តាប់ឮ អាចមើលឃើញស្គាល់ពុទ្ធបរិស័ទ ឬអាចមានថេរដីកាផ្តែផ្តាំបុត្រធីតាបាន។ ឧទាហរណ៍ៈ ព្រះអង្គប្រាប់កូនស្រីឈ្មោះ ណែត ឱ្យកោរសក់បួសជាដូនជី និងផ្តាំកូនប្រុសឈ្មោះ សុវណ្ណ ឱ្យជួយបញ្ចប់ការកសាងព្រះវិហារវត្តនៅប្រទេសកម្ពុជា ដែលព្រះអង្គពុំទាន់បានបំពេញចប់សព្វគ្រប់នៅឡើយ ដោយត្រូវការបច្ច័យ ៥០០០ដុល្លារសហរដ្ឋអាមេរិកថែមទៀតជាដើម ។ល។

ព្រះកាយវិការរបស់ព្រះសពនាពេលចុងក្រោយនេះ បានបញ្ជាក់ឱ្យឃើញថា ព្រះវិញ្ញាណរបស់ព្រះអង្គនៅតែជាប់ជំពាក់ជានិច្ចនឹងសីលទាន បុញ្ញកម្មនៅក្នុងព្រះពុទ្ធសាសនា។ នេះជាកាលសម័យដ៏ប្រសើរបំផុតសម្រាប់ដំណើរនៃព្រះវិញ្ញាណរបស់ព្រះអង្គឆ្ពោះទៅទីស្ថានបរមសុខ គឺសុខគតិភព។

នៅមុនពេលអនិច្ចធម្ម ព្រះអង្គហាក់ស្មានដឹងជាមុនអំពីកាលកំណត់នៃជីវិតរបស់ព្រះអង្គ ហត្ថទាំងគូដាក់សណ្តូកលើព្រះកាយ ព្រះឱស និងព្រះនេត្របិទជិតយ៉ាងរៀបរយ ហាក់ដូចជាព្រះអង្គកំពុងសឹងលក់ដូច្នោះឯង។ ពុទ្ធោ! ព្រះអង្គបានលាចាកលោកយើងនេះហើយ នៅក្រោមសម្លេងទ្រហោយំដ៏កងរំពងរបស់កូនចៅគួរឱ្យសង្វេគនិងរន្ធត់ក្រៃលែង។

តទៅនេះគឺជាព្រះសកម្មភាពសង្ខេបរបស់ព្រះតេជព្រះគុណ សំវរសីលោ ឡុង មាន នៅពេលព្រះអង្គនៅគង់មានព្រះជន្មនៅឡើយៈ

ក. សម្រាប់វត្តសាមគ្គីធម្មិការាម

អស់រយៈពេលជាង ២០ឆ្នាំកន្លងទៅនេះ ព្រះតេជព្រះគុណ សំវរសីលោ បានគង់ចាំព្រះវស្សាជាប្រចាំនៅក្នុងវត្តសាមគ្គីធម្មិការាម ពុំដែលបោះបង់ចោលវត្ត និមន្តទៅគង់នៅវត្តដទៃឡើយ ទោះបីត្រូវប្រឈមនឹងបញ្ហាឧបសគ្គយ៉ាងណាក៏ដោយ។ ព្រះអង្គតែងតែគង់ជាប់ជានិច្ចខាងយុត្តិធម៌។ ថ្វីត្បិតតែព្រះអង្គធ្លាប់បានលាចាកសិក្ខាបទ១ដង ២ដងហើយក្តី (វិបត្តិ)

តែពេលណាដែលអត់មានព្រះសង្ឃគង់ចាំវស្សាក្នុងវត្ត ព្រះអង្គតែងតែស្ម័គ្រព្រះទ័យវិលត្រឡប់មកវត្តវិញ បួសជាព្រះសង្ឃដឹកនាំកិច្ចការព្រះពុទ្ធសាសនា និងជួយអប់រំ ណែនាំសង្គ្រោះពុទ្ធបរិស័ទ។

វត្តសាមគ្គីធម្មិការាម ដែលមានការលូតលាស់ចម្រើនគង់វង្សស្ថិតស្ថេរមកដល់សព្វថ្ងៃនេះក៏ដោយសារតែមហាគុណូបការៈរបស់ព្រះអង្គ នេះមិនបានរៀបរាប់បញ្ចូលអំពីបច្ច័យបរិច្ចាគ និងកម្លាំងកាយ ដែលព្រះអង្គបានបូជាចំពោះវត្តក្នុងការជួសជុលតុបតែង និងកសាងវត្តផង ។ល។

ខ. សម្រាប់មាតុភូមិកម្ពុជា

នៅក្រោយពេលដែលលោកយាយ ម៉ី ស៊ីថូ ជាញោមស្រីរបស់ព្រះអង្គ បានទទួលអនិច្ចកម្មទៅ ព្រះតេជព្រះគុណតែងតែនិមន្តទៅប្រទេសកម្ពុជាជាញឹកញាប់ដោយនាំយកថ្នាំពេទ្យ សម្លៀកបំពាក់ ស្បង់ស្បៃត្រៃចីវរ...និងបច្ច័យមួយចំនួនធំ ដែលបានមកអំពីក្រុមហ៊ុនធានារ៉ាប់រងជីវិតរបស់លោកយាយ ម៉ី ស៊ីថូ រួមទាំងបច្ច័យរបស់ព្រះអង្គផ្ទាល់ផង យកទៅចែករំលែកជួយដល់ប្រជាពលរដ្ឋខ្មែរ មានកម្មករ អ្នកក្រីក្រខ្សត់ ទុគ៌ត ជរាពិការ ។ សំខាន់ជាងនេះទៅទៀតនោះ ព្រះអង្គបានយកបច្ច័យមួយចំនួនធំទៅបូជាក្នុងកិច្ចការព្រះពុទ្ធសាសនា ចូលរួមក្នុងកិច្ចការកសាងនានា ដូចមានរៀបរាប់ដោយសង្ខេបតទៅនេះ:

១.សម្រាប់វត្តពោធិ៍ទោង

បានជាវសៀវភៅគម្ពីរព្រះត្រៃបិតកមួយចប់ ដែលមាន១១០គម្ពីរនោះ និងទូមួយសម្រាប់តម្កល់គម្ពីរទាំងនោះ។

២.សម្រាប់វត្តពោធិ៍ខាវ

-បានជាវសៀវភៅគម្ពីរព្រះត្រៃបិតកមួយចប់ ដែលមាន១១០គម្ពីរនោះ និងទូមួយសម្រាប់តម្កល់គម្ពីរទាំងនោះ។

-បានជាវម៉ាស៊ីនភ្លើងមួយគ្រឿង

-បានជាវឥដ្ឋពណ៌សម្រាប់ក្រាលព្រះវិហារ

៣.សម្រាប់វត្តព្រះស្រែ

-បានជាវដីមួយគម្រោងសម្រាប់ពង្រីកទីធ្លាវត្តអារាមនេះឱ្យបានកាន់តែធំទូលំទូលាយ

-បានកសាងក្លោងទ្វារវត្ត

-បានចូលរួមជាមួយពុទ្ធបរិស័ទចំណុះជើងវត្តព្រះស្រែកសាងជណ្តើរថ្មនៃសាលាឆាន់

៤.សម្រាប់វត្តក្បឿងរាយ បានកសាងសាលាឆាន់មួយខ្នង

៥.សម្រាប់វត្តព្រាល បានជាវម៉ាស៊ីនភ្លើងមួយគ្រឿង

សមិទ្ធិផលនៅមានច្រើនទៀត ដែលបុត្រប្រុសស្រីរបស់ព្រះអង្គនៅចងចាំពុំទាន់អស់នៅពេលផ្សាយនេះ ។

ពិធីបុណ្យឈាបនកិច្ចព្រះសពវិសាមញ្ញព្រះគ្រូចៅអធិការវត្តសាមគ្គីធម្មិការាម ព្រះភិក្ខុ សំវរសីលោ មានការនិមន្ត និងអញ្ជើញចូលរួមពីសំណាក់ព្រះភិក្ខុសង្ឃ ព្រមទាំងពុទ្ធបរិស័ទចំនួន ៤វត្ត គឺវត្តជោតនារាម ខណ្ឌប្រង់ស៏ បូរីនូយ៉ក រដ្ឋនូយ៉ក វត្តព្រះពុទ្ធរង្សី ទីក្រុងហ្វីឡាដេលហ្វីយ៉ា រដ្ឋផេនស៊ីលវ៉ៃនញ៉ា វត្តព្រះពុទ្ធប្រទានពរ ទីក្រុងហ្វុឡាដេលហ្វុយ៉ា និងវត្តសាមគ្គីធម្មិការាម ទីក្រុងប្រ៊ុកលីនតែម្តង ។

មានសាមណេរថ្មីបួនអង្គ ដូនជីមួយនាក់ និងសីលវន្តី (សីល៨)បួននាក់ បួសមុខភ្លើងប្រគេនព្រះតេជព្រះគុណ សំវរសីលោ មានគឺ សាមណេរ មាស សំអុល (ជាកូនប្រុស) សាមរេ ប៉ាង សុវណ្ណរិទ្ធ (ចៅប្រុស) សាមណេរ ឡុង វណ្ណវីរៈ អេរ្វិក (ចៅប្រុស) សាមណេរ ឡុង វិសិដ្ឋ ប្រេនដិន (ចៅប្រុស) ដូនជី មាស សុផាត (កូនស្រី) សីលវន្តី ហ៊ុន រស្មី (ចៅស្រី) សីលវន្តី ហ៊ុន ដាយអេនណា (ចៅស្រី) សីលវន្តី ហ៊ុន ឌីអេនណា (ចៅស្រី) និងសីលវន្តី មាស ដេននីស (ចៅស្រី) ។

ព្រះតេជព្រះគុណ សំវរសីលោ ឡុង មាន បានបន្សល់ទុកកូនប្រុសស្រី កូនប្រសារប្រុសស្រី ព្រមទាំងចៅ៧យ៉ាងច្រើននាក់សម្រាប់បន្តពូជពង្សវង្សត្រកូលខ្មែរតទៅ ។

នៅក្នុងពេលបច្ចុប្បន្ននេះ វត្តសាមគ្គីធម្មិការាមមានព្រះសង្ឃមួយអង្គ ព្រះភិក្ខុ កល្យាណធរោ ធមិ ប៊ុនធឿន គង់នៅដឹកនាំបន្តកិច្ចការវត្តប្រចាំថ្ងៃ ។

ប្រភពព័ត៌មានៈ

វត្តសាមគ្គីធម្មិការាម និងព្រះគ្រូចៅអធិការវត្តជោតនារាម ខណ្ឌប្រង់ស៏ បូរីនូយ៉ក ព្រះភិក្ខុ វីរិយធម្មោ ពោធ កណ្ដាល

ថ្ងៃអាទិត្យ ១១ រោច ខែបុស្ស ឆ្នាំខាល ទោស័ក ព.ស.២៥៥៤ ត្រូវនឹងថ្ងៃទី ៣០ ខែមករា គ.ស. ២០១១

*ផ្សាយប្រគេននិងជូនឡើងវិញជាធម្មទាន ទូរទស្សន៏ Templenews.org*